# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ : ៧៧.៦៨ សជណ**

ថ្ងៃសុក្រ ១៤ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ** ៖ ករណីរបាយការណ៍ស្តីពីស្ថានភាព និងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរត់ពន្ធមនុស្ស។

**យោង** ៖ - លិខិតលេខ១២៥ របក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ៤៧៥ ខន/០២២ សជណ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេចក្រឡាហោម មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឃើញនិងឯកភាពដូចខាងក្រោម៖

១-បង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសង្គ្រោះជនរងគ្រោះ ស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ និងបង្ក្រាបល្បែងស៊ីសងខុសច្បាប់ដែលមានការពាក់ព័ន្ធ។

២-ចំពោះករណីដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពិតប្រាកដ ឬការជួញដូរកម្លាំងពលកម្ម ឬការឆបោកតាមប្រព័ន្ធអនឡាញ ត្រូវពន្លាតការស្រាវជ្រាវនោះសំដៅទៅរកបទល្មើសសម្អាតប្រាក់ថែមទៀត។

៣-អនុវត្តដោយស្មើភាពស្របតាមច្បាប់ជាធរមាន និងប្រកបដោយការទទួលខុសត្រូវខ្ពស់នៅគ្រប់ទីតាំងដែលសង្ស័យថាពាក់ព័ន្ធនឹងអំពើជួញដូរ និងរត់ពន្ធមនុស្សគ្រប់ទម្រង់ ដោយអនុវត្តវិធានការច្បាប់មុឺងម៉ាត់លើទីតាំង និងបុគ្គលដែលត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងបទល្មើសនេះ ហើយត្រូវទទួលរងទណ្ឌកម្មស្របតាមការកំណត់នៃច្បាប់ដោយគ្មានការលើកលែង។ទ.

៤-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការវាយបក និងឆ្លើយតបទាន់ពេលវេលារាល់ការផ្សព្វផ្សាយព័ត៌មានដែលមានចរិតញុះញង់ និងស្នើឱ្យកែតម្រូវចំណុចដែលផ្ទុយពីការពិត ដើម្បីបន្សាបឥទ្ធិពលវាយប្រហារអវិជ្ជមានពីមជ្ឈដ្ឋាននានា ទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងបញ្ចៀសផលប៉ះពាល់មកលើបរិយាកាសនយោបាយ និងសន្តិសុខសង្គម។

៥-បង្កើនកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ សំដៅត្រួតពិនិត្យ និងរៀបចំរបៀបរៀបរយនៅតាមបណ្ដាទីតាំងដែលមានការប្រមូលផ្ដុំការស្នាក់នៅ ការធ្វើអាជីវកម្ម និងការប្រើប្រាស់កម្លាំងពលកម្មជនបរទេស សំដៅគ្រប់គ្រងជនបរទេសឱ្យបានហ្មត់ចត់ និងទប់ស្កាត់ការជ្រៀតចូលដោយខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែន។

សេចក្ដីដូចបានជម្រាបជូនខាងលើសូមសម្ដេចក្រឡាហោម មេត្តាជ្រាបនិងចាត់ចែងអនុវត្ត។ S.L

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

Thyaxy

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងកិច្ចការនារី
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ